# កំណត់អត្តសញ្ញាណ និងប្រឈមនឹងការបំផ្លែងទ្រង់ទ្រាយ Holocaust៖ មេរៀនសម្រាប់អាស៊ីអាគ្នេយ៍

អំពើប្រល័យពូជសាសន៍នៅក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ បានផ្តោតជាពិសេសទៅលើជនជាតិជ្វីហ្វ និងរ៉ូម៉ា ប៉ុន្តែខ្លឹមសាររបស់វាគឺមានលក្ខណៈជាសកល។ ការបដិសេធចំពោះ **Holocaust** គឺជាទម្រង់មួយនៃការបដិសេធន៍អំពើប្រល័យពូជសាសន៍ ដែលមានគ្រោះថ្នាក់នៅទូទាំងពិភពលោក។ មានឧទាហរណ៍ជាច្រើន ស្តីពីការបំផ្លែងទ្រង់ទ្រាយ **Holocaust** នៅអាស៊ីអាគ្នេយ៍។ គម្រោងនេះទាក់ទងនឹងទម្រង់ផ្សេងៗគ្នានៃការបដិសេធន៍ និងការបំផ្លែងទ្រង់ទ្រាយ **Holocaust** ដែលសាយភាយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ឧទាហរណ៍ ការប្រើប្រាស់រូបនិមិត្តសញ្ញារបស់ណាហ្ស៊ី ប្រក្រតីរូបនីយកម្មនៃរូបភាពរបស់ហ៊ីត្លែរនិងណាហ្ស៊ីអាល្លឺម៉ង់ឲ្យមានលក្ខណៈធម្មតានៅក្នុងវប្បធម៌មហាជន។ ទ្រឹស្តីឃុបឃិតទម្លាក់កំហុសលើជនជាតិភាគតិច និងបន្ទោសជនរងគ្រោះ(រួមទាំងជ្វីហ្វ) ចំពោះបទឧក្រិដ្ឋ និងជម្លោះប្រវត្តិសាស្ត្រកន្លងមក។ ការធ្វើសាកលភាវូបនីយកម្មប្រកបដោយគ្រោះថ្នាក់នៃការបដិសេធមិនទទួលស្គាល់ថាមានអំពើប្រល័យពូជសាសន៍ រួមទាំងការកើនឡើងនៃ«ពហុសកម្មជនប្រឆាំង» ដែលបំផ្លែងទ្រង់ទ្រាយទាំងឧក្រិដ្ឋកម្មណាហ្ស៊ី និងករណីអំពើប្រល័យពូជសាសន៍ផ្សេងទៀត ដូចជាឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ឬអំពើហិង្សាប្រឆាំងនឹងជនជាតិរ៉ូហ៊ីងយ៉ា។ គម្រោងនេះផ្តោតលើបទពិសោធន៍ក្នុងតំបន់អំពីសង្គ្រាមលោកលើកទីពីរ និងករណីអំពើប្រល័យពូជសាសន៍បន្ថែមទៀត នៅក្នុងប្រទេសកម្ពុជា ប្រទេសភូមា និងប្រទេសថៃ ដើម្បីជំរុញការជជែកពិភាក្សាសំខាន់ៗក្នុងការចងចាំ និងអភិវឌ្ឍសមត្ថភាពក្នុងការប្រឆាំងនឹងការបំផ្លែងនៃ **Holocaust** និងការប្រល័យពូជសាសន៍នៅក្នុងតំបន់។ ទស្សនិកជនរបស់គម្រោងមានភាពចម្រុះ ដោយរួមបញ្ចូលទាំងអ្នកបង្កើតគំនិត និងអ្នកដឹកនាំជាច្រើនដូចជា មេដឹកនាំខាងជំនឿ បុគ្គលិកសារមន្ទីរ និងអ្នកធ្វើការនៅទីតាំងបូជណីដ្ឋាន ព្រមទាំងកន្លែងផ្សេងៗទៀត។ សកម្មភាពរបស់គម្រោងរួមមាន ការស្រាវជ្រាវ សិក្ខាសាលា ការតាំងពិព័រណ៍ឌីជីថល ការបោះពុម្ពផ្សាយ និងការលើកកម្ពស់ការយល់ដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។ គំនិតរបស់គម្រោងចេញមកពីការផ្តួចផ្តើមនៅក្នុងតំបន់ខ្លួនឯង ហើយត្រូវបានបង្កើតឡើងដោយការសហការជាមួយអ្នកគាំទ្រក្នុងស្រុក និងដៃគូរបស់សមាគម“**Never Again**” ។

“**Never Again**” មានបទពិសោធន៍យ៉ាងទូលំទូលាយនៅក្នុងសកម្មភាពនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ តាមរយៈសិក្ខាសាលាស្តីពី **Holocaust** សម្រាប់ទស្សនិកជនក្នុងតំបន់ យើងបានកំណត់នូវបញ្ហាប្រឈម និងការយល់ច្រឡំទ្រង់ទ្រាយធំ ហើយយើងបង្កើតទន្និករណ៍ដើម្បីប្រឈម និងមធ្យោបាយឆ្លើយតបទៅនឹងបញ្ហាទាំងនេះ។

The project has been supported by គាំទ្រគម្រោងដោយ the International Holocaust Remembrance Alliance (IHRA)

Main project partner: Heinrich Böll Stiftung Cambodia
ដៃគូចម្បងនៃគម្រោង៖មូលិនិធិហែនរិចបូលកម្ពុជា